00353500

E107/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 22 / JUL / 2009
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧-អវតក/អជសដ
**Case File/Dossier No. 001/18-07-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម **យ៉ា សុខន**
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **ធូ មណី**

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certifified Date/Date de certification): 22 / 07 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

កាលបរិច្ឆេទ: ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០០៩
ចំណាត់ថ្នាក់ឯកសារ សាធារណៈ:

# សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យចាត់ថ្នាក់សំណើរបស់មេធាវីការពារក្តីជា "សម្ងាត់" ទាក់ទងនឹងសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង

**សហព្រះរាជអាជ្ញា**
ជាលាង
Robert PETIT

**ជនជាប់ចោទ**
កាំង ហ្គេកអ៊ាវ ហៅ ឌុច

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE
ទី ស្រីនណា
Pierre Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE
Elizabeth RABESANDRATANA
Karim KHAN

**មេធាវីជនជាប់ចោទ**
ការ សាវុត្ថ
François ROUX
Marie-Paule CANIZARES

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសជ តាម "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច" ដែលអង្គបុរេជំនុំជម្រះបានសម្រេច និងប្រកាសនៅថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០០៨ និងបានដាក់សេចក្តីសម្រេចនេះជាភាសាខ្មែរទៅក្នុងសំណុំរឿងនៅថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០០៨[1]។

**ក្រោយពីបានទទួល** សំណើសុំរបស់មេធាវីការពារក្តីកាលពីថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៩។

**ក្រោយពីបានទទួល** សំណើរបស់សហព្រះរាជអាជ្ញាកាលពីថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៩ ស្នើសុំធ្វើសវនាការជាអសាធារណៈដើម្បីពិភាក្សាបញ្ហានៃការមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងរបស់សាក្សីស្របតាមវិធាន ២៨(៨) នៃវិធានផ្ទៃក្នុង។

**ក្រោយពីបានស្តាប់** ការអះអាងរបស់ភាគីក្នុងពេលសវនាការជាអសាធារណៈកាលពីថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០០៩។

**រំលឹកឡើងវិញ** សេចក្តីសម្រេចដោយផ្ទាល់មាត់របស់អង្គជំនុំជម្រះកាលពីថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៩។

**អនុលោមតាម** វិធាន ២៨(៨) និងវិធាន ៧៩(៦) នៃវិធានផ្ទៃក្នុង។

## អង្គហេតុ និង សំអាងហេតុ

១. សហព្រះរាជអាជ្ញាបានស្នើសុំធ្វើសវនាការជាអសាធារណៈដោយផ្អែកលើវិធាន២៨(៨) នៃវិធានផ្ទៃក្នុងដើម្បីពិភាក្សាលើការចាត់ថ្នាក់ឯកសារដែលបានដាក់ដោយមេធាវីការពារក្តីកាលពីថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៩។ នៅក្នុងសារណារបស់ខ្លួនសហព្រះរាជអាជ្ញាបានស្នើសុំអោយធ្វើ

[1] "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច" ថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០០៨ (ឯកសារ D99/3/42)។

ការចាត់ថ្នាក់ឯកសារថា "សម្ងាត់" នៅពេលដែលឯកសារខាងលើនឹងត្រូវដាក់ចូលក្នុងសំណុំរឿង។

២. យោងលើសេចក្តីណែនាំអនុវត្តលេខ ០០៤ ឆ្នាំ២០០៩ ស្តីពី"ការចាត់ថ្នាក់ឯកសារ និងការគ្រប់គ្រងសំណុំរឿងទាក់ទងនឹងព័ត៌មាន" អង្គជំនុំជម្រះមានកតព្វកិច្ចក្នុងការធ្វើចំណាត់ថ្នាក់លើប្រភេទឯកសារមួយចំនួនទៅលើឯកសារដែលបានដាក់ទៅជា "សាធារណៈ" "សម្ងាត់" ឬ "សម្ងាត់បំផុត"។ មុនពេលដែលមានការចាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះនោះ ឯកសារទាំងអស់ត្រូវសន្មត់ថាមានភាពសម្ងាត់។ អង្គជំនុំជម្រះមានរយៈពេល ៣០ ថ្ងៃ ក្នុងការធ្វើការចាត់ថ្នាក់ឯកសារដែលភាគីដាក់ចំពោះមុខខ្លួន។ គិតមកដល់ពេលនេះ រយៈពេលដែលបានកំណត់នេះមិនទាន់ផុតរលត់នៅឡើយទេ។

៣. មានប្រភេទឯកសារពីរដែលត្រូវបានដាក់ចូលក្នុងសំណុំរឿង។ ប្រភេទឯកសារទីមួយគឺជាប្រភេទឯកសារដែលត្រូវបានគេសន្មត់ថាមានភាពសម្ងាត់ រីឯប្រភេទឯកសារទីពីរគឺជាប្រភេទឯកសារដែលត្រូវបានគេសន្មត់ថាជាសាធារណៈ។ ប្រភេទទីមួយគឺការផ្សព្វផ្សាយមានកម្រិតសម្រាប់បុគ្គលដែលមានការការពាក់ព័ន្ធមួយចំនួនប៉ុណ្ណោះ។

៤. ដោយធ្វើការពិចារណាទៅលើសំណើសុំដែលបានស្នើឡើងដោយមេធាវីការពារក្តី អង្គជំនុំជម្រះយល់ឃើញថាគ្មានមូលហេតុណាដែលសំណើនេះត្រូវចាត់ថ្នាក់ថា "សម្ងាត់នោះ" ឡើយ។ សំណើនេះមិនស្ថិតក្នុងប្រភេទនៃកសារដែលមិនមែនមិនត្រូវបានចាត់ថ្នាក់ជាសាធារណៈនោះឡើយ។

៥. អង្គជំនុំជម្រះកត់សម្គាល់ឃើញផងដែរថាវិធាន ២៨(៨) នៃវិធានផ្ទៃក្នុង អាចនឹងត្រូវបានលើកឡើងតែក្នុងករណីដែលមានបញ្ហាទាក់ទងនឹងការមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងប៉ុណ្ណោះ។ ដោយហេតុថានេះជាការលើកលែងមួយទៅនឹងគោលការណ៍នៃការធ្វើសវនាការជាសាធារណៈដែលមានចែងនៅក្នុងវិធាន៧៩(៦)នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងអាចរៀបចំធ្វើសវនាការជាអសាធារណៈដើម្បីពិចារណាទៅលើបញ្ហាដែលបានលើកឡើងទាក់ទងនឹងវិធានខាងលើនេះ។ សំណើដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញាមិនស្ថិតនៅក្នុងប្រភេទនៃបញ្ហាដែលត្រូវ



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C

00353503



ធ្វើសវនាការជាអសាអសាធារណៈនោះឡើយ អាស្រ័យហេតុនេះ អង្គជំនុំជម្រះត្រូវធ្វើការប្រកាសសេចក្ដីសម្រេចរបស់ខ្លួនជាសាធារណៈ។

៦. នៅទីបញ្ចប់ អង្គជំនុំជម្រះរំលឹកដល់ភាគីនានាថាភារៈកិច្ចក្នុងការលើកឡើងអំពីការមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងរបស់សាក្សីគឺជាបន្ទុករបស់អង្គជំនុំជម្រះសាលាដំបូង ឬជាបន្ទុករបស់មេធាវីប្រឹក្សាសម្រាប់សាក្សី។ មេធាវីការពារក្ដីមិនត្រូវលើកឡើងវិញដដែលៗទៀតអំពីការមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងចំពោះសាក្សីដែលនឹងត្រូវផ្ដល់សក្ខីកម្មនាពេលខាងមុខឡើយ។

## ហេតុដូច្នេះសម្រេច÷

១. សំណើសុំរបស់មេធាវីការពារក្ដីនឹងត្រូវចាត់ថ្នាក់ថាជាប្រភេទឯកសារសាធារណៈនៅពេលដែលដាក់ចូលក្នុងសំណុំរឿង។

២. សវនាការជាអសារណៈដែលបានធ្វើឡើងកាលពីថ្ងៃទី ២០ ខែកក្កដា គឺជាសវនាការមួយដែលមិនគួរស្នើសុំឡើយព្រោះថាប្រធានបទដែលបានស្នើសុំពិភាក្សានោះមិនឆ្លុះបញ្ចាំងនូវខ្លឹមសារចង្អៀតនៃ វិធាន ២៨(៨) នៃវិធានផ្ទៃក្នុងនោះទេ។

៣. អង្គជំនុំជម្រះនឹងបន្តដោយធានាថាសាក្សីដែលអង្គជំនុំជម្រះយល់ឃើញថាអាចមានហានិភ័យក្នុង ការធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងនោះនឹងត្រូវទទួលបាននូវការប្រឹក្សាយោបល់ផ្នែកច្បាប់ និងជម្រាបជាមុនដោយអង្គជំនុំជម្រះស្របតាមវិធាន ២៨ នៃវិធានផ្ទៃក្នុង។ មេធាវីការពារក្ដី ចាប់ពីពេលនេះតទៅ មិនត្រូវជម្រាបដល់សាក្សីអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប នៅពេលដែលសាក្សីត្រូវផ្ដល់សក្ខីកម្មនៅចំពោះមុខតុលាការឡើយ។

ភ្នំពេញ ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០០៩

ប្រធានអង្គជំនុំជម្រះសាលាដំបូង

និល - ណុន